# អាទិត្តជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**អសទិសទាន** (ទានដែលឥតមានទានដទៃណាមួយប្រដូចបាន) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា អាទិត្តស្មឹំ ដូច្នេះជាដើម ។

អសទិសទាននេះមានសេចក្តីពិស្តារហើយក្នុងអដ្ឋកថាមហាគោវិន្ទសូត្រ ។ ក្នុងថ្ងៃទី ២ អំពីថ្ងៃថ្វាយអសទិសទាន ភិក្ខុទាំងឡាយញុាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា "ម្នាលអាវុសោ ព្រះបាទកោសលពិចារណាជ្រើសរើសលៃលក បានដឹងនូវបុញ្ញក្ខេត្តហើយ ទើបថ្វាយអសទិសទានដល់ព្រះអរិយសង្ឃដែលមានព្រះពុទ្ធជាប្រធាន" ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នា

និយាយរឿងអ្វី ?” កាលពួកភិក្ខុទូលថា “រឿងនេះ” ទើបព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មិនជាអស្ចារ្យទេ ដែលព្រះរាជាពិចារណាលែលកជ្រើសរើសហើយញុំាំងទានឲ្យតាំងនៅក្នុងបុញ្ញក្ខេត្តដ៏ប្រសើរនោះ សូម្បីបោរាណកបណ្ឌិតទាំងឡាយក៏បានពិចារណាលែលកជ្រើសរើសហើយឲ្យមហាទានដែរ” ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសម្ដែងថា

ក្នុងអតីតកាល ព្រះរាជាព្រះនាម **ពោរុរមហារាជ** ក្នុងពោរុនគរ ទ្រង់មិនធ្វើទសរាជធម៌ឲ្យកម្រើក, ទ្រង់សង្គ្រោះប្រជានុរាស្ត្រដោយសង្គហវត្ថុ ៤, ទ្រង់ឋិតនៅក្នុងឋានៈមាតាបិតាដល់មហាជន, ញុំាំងមហាទានឲ្យប្រព្រឹត្តទៅដល់មនុស្សកំព្រា អ្នកដំណើរ វណិព្វកៈ (អ្នកពណ៌នាហើយទើបសូម) និងអ្នកស្មូម ។ ព្រះអគ្គមហេសីរបស់ព្រះរាជានោះ មានព្រះនាមថា **សមុទ្ទវិជយា** ព្រះនាងជាបណ្ឌិតបរិបូណ៌ដោយបញ្ញា ។

ថ្ងៃមួយ ព្រះបាទពោរុរមហារាជសម្លឹងមើលរោងទាន ទ្រង់គិតថា “បដិគ្គាហកៈទាំងឡាយជាសត្វឡេះឡោះទ្រុស្តសីលបរិភោគទានរបស់យើង, ទាននោះមិនញុំាំងយើងឲ្យត្រេកអរឡើយ, យើងប្រាថ្នាឲ្យទានដល់ព្រះបច្ចេកពុទ្ធដែលជាអ្នកមានសីល និងជាអគ្គទក្ខិណេយ្យបុគ្គល, តែព្រះបច្ចេកពុទ្ធទាំងនោះលោកគង់នៅក្នុងហិមវន្តប្រទេស, អ្នកណានឹងទៅនិមន្តលោកឲ្យមក, តើយើងនឹងបញ្ជូនអ្នកណាឲ្យទៅ” គិតរួច ព្រះរាជាប្រាប់សេចក្ដីនោះដល់ព្រះទេវី ។

លំដាប់នោះ ព្រះនាងសមុទ្ទវិជយាទូលព្រះរាជាថា “បពិត្រមហារាជ សូមព្រះអង្គកុំគិតឡើយ, ដោយកម្លាំងទានយើងគប្បីឲ្យ ដោយកម្លាំងសីល ដោយកម្លាំងសច្ចៈ យើងនឹងបញ្ជូនផ្កាឲ្យទៅនិមន្តព្រះបច្ចេកពុទ្ធទាំងនោះ ហើយឲ្យទានព្រមទាំងបរិក្ខារទាំងពួងដល់លោកដែលមកហើយ” ។ ព្រះរាជាទទួលថា “ប្រពៃហើយ” រួចទ្រង់ឲ្យរាជបុរសត្រាច់វាយស្គរស្រែកប្រកាសក្នុងនគរថា “អ្នកនគរទាំងអស់ចូរសមាទានសីល”ចំណែកព្រះរាជានិងបរិវារអធិដ្ឋានអង្គឧបោសថរួចហើយ ញុំាំងមហាទានឲ្យប្រព្រឹត្តទៅ ឲ្យគេយកស្មុគមាសដែល

ពេញដោយផ្កាម្ទិះ ទ្រង់ចុះចាកប្រាសាទ ឋិតនៅត្រង់ព្រះលានហ្លួង ប្រតិស្ឋានអង្គទាំង ៥ លើផែនដី មានមុខបែរទៅរកទិសខាងកើត ស្ដេចថ្វាយបង្គំ ហើយត្រាស់ថា "ខ្ញុំសូមថ្វាយបង្គំព្រះអរហន្តដែលនៅក្នុងទិសខាងកើត, បើគុណយ៉ាងណាមួយរបស់ខ្ញុំមាន, សូមលោកម្ចាស់ទាំងឡាយធ្វើសេចក្ដីអនុគ្រោះខ្ញុំ និងសូមទទួលភិក្ខារបស់ខ្ញុំ" ប្រកាសរួចទ្រង់បាចផ្កា៧ក្ដាប់។ ក្នុងថ្ងៃស្អែក មិនមានព្រះបច្ចេកពុទ្ធមក ព្រោះក្នុងទិសខាងកើតមិនមានព្រះបច្ចេកពុទ្ធ ។ ក្នុងថ្ងៃទី ២ ព្រះរាជានមស្ការនូវទិសខាងត្បូង, ព្រះបច្ចេកពុទ្ធមិនមកសូម្បីអំពីទិសនោះ ។ ក្នុងថ្ងៃទី ៣ ព្រះរាជានមស្ការនូវទិសខាងលិច, ព្រះបច្ចេកពុទ្ធមិនមកសូម្បីអំពីទិសនោះ ។ ក្នុងថ្ងៃទី ៤ ព្រះរាជានមស្ការនូវទិសខាងជើង ស្ដេចនមស្ការអារាធនាថា "ព្រះបច្ចេកពុទ្ធទាំងឡាយដែលគង់នៅឧត្តរហិមវន្តប្រទេស សូមទទួលភិក្ខារបស់ខ្ញុំ "ប្រកាសរួចទ្រង់បាចផ្កា ៧ ក្ដាប់ ។ ផ្កាទាំងឡាយអណ្ដែតទៅធ្លាក់លើព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលនៅនឹងញកភ្នំនន្ទមូលក៍ ។

ព្រះបច្ចេកពុទ្ធទាំងនោះពិចារណាដឹងភាពដែលព្រះរាជានិមន្តខ្លួន, ថ្ងៃស្អែក និយាយនឹងព្រះបច្ចេកពុទ្ធ ៧ អង្គថា "ម្នាលអ្នកនិរទុក្ខទាំងឡាយ ព្រះរាជានិមន្តពួកលោក ពួកលោកចូរធ្វើសេចក្ដីសង្គ្រោះព្រះអង្គ" ។ ព្រះបច្ចេកពុទ្ធទាំង ៧ អង្គនោះហោះមកតាមអាកាស ចុះត្រង់រាជទ្វារ ។ ព្រះរាជាឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ទ្រង់មានសេចក្ដីសោមនស្ស ថ្វាយបង្គំ និមន្តឲ្យឡើងកាន់ប្រាសាទ ធ្វើសក្ការៈយ៉ាងធំ ហើយថ្វាយទាន, កាលព្រះបច្ចេកពុទ្ធធ្វើភត្តកិច្ចរួចហើយ ព្រះរាជាក៏និមន្តដើម្បីប្រយោជន៍ក្នុងថ្ងៃស្អែក អស់ ៦ ថ្ងៃទៀត, ក្នុងថ្ងៃទី ៧ ព្រះរាជាចាត់ចែងទាននិងបរិក្ខារទាំងពួង រៀបចំរតនៈ ៧ ប្រការដែលឆ្នៃហើយ រៀបចំគ្រែនិងតាំងជាដើម តម្កល់ត្រៃចីវរជាដើម និងគ្រឿងប្រើប្រាស់របស់សមណៈទាំងពួង ក្នុងសំណាក់ព្រះបច្ចេកពុទ្ធទាំង ៧ អង្គ រួចពោលថា "យើងខ្ញុំសូមថ្វាយបរិក្ខារទាំងនេះដល់លោក" ដូច្នេះហើយ កាលព្រះបច្ចេកពុទ្ធធ្វើភត្តកិច្ចចប់ ព្រះរាជានិងព្រះទេវីទាំងពីរឈរនមស្ការ ។

*លំដាប់នោះ ព្រះបច្ចេកពុទ្ធជាសង្ឃត្ថេរកាលធ្វើអនុមោទនាដល់ព្រះរាជានោះ ទើបពោល ២ គាថាថា*

**អាទិត្តស្មឹ អគារស្មឹ, យំ នីហរតិ ភាជនំ;**
**តំ តស្ស ហោតិ អត្ថាយ, នោ ច យំ តត្ថ ឌយ្ហតិ ។**

*កាលបើផ្ទះត្រូវភ្លើងឆេះហើយ បុគ្គលនាំចេញនូវភាជន៍ណាទាន់ ភាជន៍នោះ រមែងបានជាប្រយោជន៍នៃបុគ្គលនោះ ភាជន៍ណាដែលភ្លើងឆេះក្នុងផ្ទះ នោះភាជន៍មិនបានជាប្រយោជន៍ នៃបុគ្គលនោះ*
*ឡើយ ។*

**ឯវមាទីបិតោ លោកោ, ជរាយ មរណេន ច;**
**នីហរេថេវ ទានេន, ទិន្នំ ហោតិ សុនីហតំ ។**

*សត្វលោក កាលបើត្រូវជរា និងមរណៈ ឆេះយ៉ាងនេះហើយ បុគ្គលគួរតែនាំចេញនូវទ្រព្យ ដោយកាឲ្យទាន (ព្រោះ) ទ្រព្យដែលបុគ្គលបានឲ្យហើយ ឈ្មោះថានាំចេញហើយដោយប្រពៃ ។*

*ព្រះបច្ចេកពុទ្ធជាសង្ឃត្ថេរធ្វើអនុមោទនាយ៉ាងនេះហើយ ឲ្យឱវាទព្រះរាជាថា " បពិត្រមហារាជ សូមព្រះអង្គកុំប្រមាទ" រួចហើយក៏ហោះឡើងលើអាកាស ធ្វើកំពូលប្រាសាទឲ្យញែកជាពីរ ហោះទៅចុះនៅនឹងញកភ្នំនន្ទមូលក៍ ។ សូម្បីបរិក្ខារដែលព្រះរាជាថ្វាយដល់ព្រះបច្ចេកពុទ្ធនោះ ក៏អណ្តែតទៅជាមួយនឹងលោក ហើយធ្លាក់ចុះនៅនឹងញកភ្នំនន្ទមូលក៍នោះដែរ ។ សរីរៈរបស់ព្រះរាជានិងព្រះទេវីពេញដោយបីតិ ។*

*ចំណែកព្រះបច្ចេកពុទ្ធដ៏សេស កាលនឹងយាងទៅបានពោលយ៉ាងនេះថា*

**យោ ធម្មលទ្ធស្ស ទទាតិ ទានំ, ឧដ្ឋានវីរិយាធិគតស្ស ជន្តុ;**
**អតិក្កម្ម សោ វេតរណឹ យមស្ស, ទិព្ពានិ ឋានានិ ឧបេតិ មច្ចោ ។**

*សត្វណា បានឲ្យទានដល់បុគ្គលអ្នកបានធម៌ បានត្រាស់ដឹងធម៌ ដោយសេចក្ដីព្យាយាម គឺការប្រឹងប្រែង សត្វនោះ រមែងប្រព្រឹត្តកន្លងនូវវេតរណី របស់យមៈ (នរក) បានហើយ ចូលទៅកាន់ទីទាំងឡាយជាទិព្វ ។*

*ពាក្យថា* ***រមែងប្រព្រឹត្តកន្លងនូវវេតរណី*** *សេចក្ដីថា ត្រឹមតែជាប្រធានទេសនាប៉ុណ្ណោះ អធិប្បាយថា រមែងប្រព្រឹត្តកន្លងនូវមហានរក ៨ រណ្ដៅ និងឧស្សទនរក ១៦ រណ្ដៅ ។*

**ទានញ្ច យុទ្ធញ្ច សមានមាហុ, អប្បាបិ សន្តា ពហុកេ ជិនន្តិ;**
**អប្បម្បិ ចេ សទ្ទហានោ ទទាតិ, តេនេវ សោ ហោតិ សុខី បរត្ថ ។**

*អ្នកប្រាជ្ញទាំងឡាយពោលថា ទាននិងចម្បាំងជារបស់ស្មើគ្នា ពួកជនសូម្បីតិចគ្នា តែជាអ្នកស៊ូលះបង់ជីវិត រមែងឈ្នះជនច្រើននាក់បាន បុគ្គលណាកាលបើជឿហើយឲ្យទានសូម្បីបន្តិចបន្តួច បុគ្គលនោះ រមែងបាននូវសេចក្ដីសុខ ក្នុងលោកខាងមុខ ដោយទេយ្យវត្ថុមានប្រមាណតិចនោះ ។*

*ពាក្យថា* ***ទាននិងចម្បាំងជារបស់ស្មើគ្នា*** *សេចក្ដីថា អ្នកប្រាជ្ញទាំងឡាយពោលថា ពិតមែន ទានរមែងមិនមានដល់អ្នកដែលភ័យខ្លាចអស់, ចម្បាំងក៏រមែងមិនមានដល់អ្នកដែលភ័យខ្លាចអស់ដែរ ។ បុគ្គលរមែងលះបង់សេចក្ដីអាល័យក្នុងជីវិតហើយច្បាំង ទើបអាចច្បាំងបាន, ទាយករមែងលះបង់សេចក្ដីអាល័យក្នុងភោគៈ ទើបអាចឲ្យបាន ដូចគ្នាដែរ ព្រោះហេតុនោះ ទាននិចម្បាំងទាំងពីរនេះ ទើបជារបស់ស្មើគ្នា ។*

**វិចេយ្យ ទានំ សុគតប្បសត្ថំ, យេ ទក្ខិណេយ្យា ឥធ ជីវលោកេ;**
**ឯតេសុ ទិន្នានិ មហប្ផលានិ, ពីជានិ វុត្តានិ យថា សុខេត្តេ ។**

ការពិចារណាសិនហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ពួកទក្ខិណេយ្យបុគ្គលណា មាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ពួកទក្ខិណេយ្យបុគ្គលនុ៎ះ មានផលច្រើន ដូចជាពូជដែលគេសាបព្រោះក្នុងស្រែដ៏ល្អ ។

យោ បាណភូតានិ អហេឋយំ ចរំ, បរូបវាទា ន ករោតិ បាបំ;
ភីរុំ បសំសន្តិ ន តត្ថ សូរំ, ភយា ហិ សន្តោ ន ករោន្តិ បាបំ ។

បុគ្គលណា មិនបៀតបៀនទូវពួកសត្វ មិនធ្វើនូវបាប ព្រោះ ( ខ្លាច) ការតិះដៀលអំពីអ្នកដទៃ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកខ្លាចបាប មិនសរសើរនូវបុគ្គលអ្នកក្លៀវក្លាក្នុងការធ្វើបាបនោះឡើយ ដ្បិតសប្បុរសទាំងឡាយ តែងមិនធ្វើបាប ព្រោះខ្លាច ( ពាក្យតំណិះដំណៀលនោះ) ។

ហីនេន ព្រហ្មចរិយេន, ខត្តិយេ ឧបបជ្ជតិ;
មជ្ឈិមេន ច ទេវត្តំ, ឧត្តមេន វិសុជ្ឈតិ ។

បុគ្គលចូលទៅកើតក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោកទាប បុគ្គលចូលទៅកាន់ភាពជាទេវតា ដោយព្រហ្មចរិយធម៌យ៉ាងកណ្តាល បុគ្គលបរិសុទ្ធ ដោយព្រហ្មចរិយធម៌ដ៏ឧត្តម ។

ពាក្យថា **ដោយព្រហ្មចរិយធម៌ដ៏ថោកទាប** សេចក្តីថា ក្នុង**ពាហិរតិត្ថាយតនៈ** (ពាហិរសាសនាខ្វះ) សីលដែលវៀរចាកមេថុន ឈ្មោះថា ព្រហ្មចរិយថ្នាក់ទាប, ដោយព្រហ្មចរិយៈនោះ រមែងកើតក្នុងខត្តិយត្រកូល ។ ឧបចារជ្ឈាន ឈ្មោះថា ព្រហ្មចរិយថ្នាក់កណ្តាល, ដោយព្រហ្មចរិយៈនោះ រមែងកើតក្នុងទេវលោក ។ សមាបត្តិ ៨ ឈ្មោះថាព្រហ្មចរិយៈថ្នាក់ឧត្តម, ដោយព្រហ្មចរិយៈនោះ រមែងកើតក្នុងព្រហ្មលោក ។ ចំណែកក្នុងព្រះពុទ្ធសាសនា សីលដែលបុគ្គលសមាទានដោយការប្រាថ្នាទេវនិកាយ ឈ្មោះថា ព្រហ្មចរិយៈថ្នាក់ទាប, ការកើតឡើងនៃសមាបត្តិរបស់អ្នកមានសីលបរិសុទ្ធនោះឯង ឈ្មោះថា ព្រហ្មចរិយៈថ្នាក់

កណ្ដាល, ការរក្សាសីលឲ្យបរិសុទ្ធ ហើយចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ឈ្មោះ ថា ព្រហ្មចរិយៈថ្នាក់ឧត្ដម ។

**អន្នា ហិ ទានំ ពហុធា បសត្ថំ, ទានា ច ខោ ធម្មបទំវ សេយ្យោ;**
**បុព្ពេវ ហិ បុព្ពតរេវ សន្តោ, និព្ពានមេវជ្ឈគមុំ សបញ្ញា ។**

*ការឲ្យទាន ពិតជាអ្នកប្រាជ្ញសរសើរ ដោយចំណែកច្រើន ក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះ ប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញា ក្នុងកាលមុន និង កាលមុនទៅទៀតបានត្រាស់ដឹងនូវនិព្វានធម៌ ។*

ព្រះបច្ចេកពុទ្ធ ៦ អង្គដ៏សេសបានធ្វើការអនុមោទនាដោយគាថាមួយៗយ៉ាងនេះ ហើយ ចំណែកបរិក្ខារក៏អណ្ដែតទៅតាមលោកយ៉ាងនោះដែរ ។

គាថាចុងក្រោយនេះមានសេចក្ដីអធិប្បាយថា បពិត្រមហារាជ បើបុគ្គលណាមួយ ពោលសរសើរទានដោយប្រការយ៉ាងច្រើន ប៉ុន្តែធម្មបទប៉ុណ្ណោះ ដែលឲ្យកើតធម្មកោដ្ឋាសៈ ពោលគឺសមថៈនិងវិបស្សនានោះឯង រមែងប្រសើរក្រៃលែងជាងទាន ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា សូម្បីក្នុងកាលមុន ក្នុងកប្បនេះ សប្បុរសទាំងឡាយដែលជាអ្នកស្ងប់ មានព្រះពុទ្ធកស្សបទសពលជាដើម ឬ ក្នុងកាលមុនជាងនេះទៅទៀត មានព្រះពុទ្ធវេស្សភូទសពល ជាដើម ព្រះអង្គជាអ្នកមានបញ្ញាចម្រើនសមថវិបស្សនា ហើយបានបន្ទុះព្រះនិព្វាន ។

ព្រះបច្ចេកពុទ្ធទាំង ៧ អង្គ ពោលសរសើរអមតមហានិព្វាន ដល់ព្រះរាជា ដោយការ អនុមោទនាយ៉ាងនេះហើយ ឲ្យឱវាទដល់ព្រះរាជាដោយសេចក្ដីមិនប្រមាទរួចហើយ ទើប ទៅកាន់លំនៅរបស់ខ្លួនៗ ដោយន័យដែលបានពោលហើយនោះឯង ។ ចំណែកព្រះរាជា និងព្រះអគ្គមហេសី ទ្រង់ឲ្យទាន និងបិតនៅរហូតដល់អស់អាយុ ក្រោយអំពីចុតិ បានកើត ក្នុងឋានសួគ៌ ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា "បណ្ឌិតទាំងឡាយសូម្បីក្នុងកាលមុន បានពិចារណាជ្រើសរើសហើយ ក៏ឲ្យទានដែរ" រួចទ្រង់ប្រជុំជាតកថា

តទា បច្ចេកពុទ្ធា បរិនិព្ពាយិំសុ ព្រះបច្ចេកពុទ្ធទាំងឡាយក្នុងនោះបរិនិព្វានហើយ

សមុទ្ទវិជយា រាហុលមាតា អហោសិ នាងសមុទ្ទវិជយា បានមកជារាហុលមាតា

ពេរុវមហារាជា បន អហមេវ អហោសិំ ចំណែកព្រះបាទពេរុវមហារាជ គឺតថាគតនេះឯង ។

អាទិត្តជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក អដ្ឋកនិបាត អាទិត្តជាតក បិដកលេខ ៥៩ ទំព័រ ១២៨)

ថ្ងៃសុក្រ ៦ រោច ខែវិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ត្រូវនឹងថ្ងៃទី ២៤ ខែឧសភា គ.ស. ២០១៩

ដោយសដវថ